**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ...[illegible]...សនប

# ប្រកាស

## ស្តីពី

## ការកែសំរួលប្រការ៥ នៃប្រកាសលេខ ០៧៧ សនប ស្តីពីការធ្វើប្រតិភូកម្មមុខងារនៃវិស័យសុខាភិបាល ជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈរបស់ក្រសួងសុខាភិបាល

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខនស /រកត០៩១៣ / ៩០៣ចុះថ្ងៃទី២៤ខែកញ្ញាឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ /នស /៩៤ ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស / រកម / ០១៩៦ / ០៦ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រមលេខនស /រកម / ១១០០ /១០ចុះថ្ងៃទី០៣ខែវិច្ឆិកាឆ្នាំ២០០០ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រអមវេជ្ជសាស្ត្រនិងជំនួយវេជ្ជសាស្ត្រ

-បានឃើញអនុក្រឹត្យលេខ៦៧អនក្រ.បកចុះថ្ងៃទី២២ខែតុលាឆ្នាំ១៩៩៧ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-បានឃើញអនុក្រឹត្យលេខ៦៨អនក្រ.បកចុះថ្ងៃទី១០ខែឧសភាឆ្នាំ២០១២ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារនិងធនធានឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-បានឃើញអនុក្រឹត្យលេខ៦៨អនក្រ.បកចុះថ្ងៃទី២១ខែកុម្ភៈឆ្នាំ២០១៣ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-បានឃើញសេចក្តីសម្រេចលេខ១២សសរចុះថ្ងៃទី៣០ខែមិថុនាឆ្នាំ២០០៨របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយនិងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌ

-បានឃើញប្រកាសលេខ០០១៤អបស / ឱអបសចុះថ្ងៃទី១៣ខែមករាឆ្នាំ២០០៩ស្តីពីបែបបទនិងល័ក្ខខ័ណ្ឌក្នុងការសុំបើកឬបិទឬសុំប្តូរទីតាំងនៃគ្រឹះស្ថានលក់ឱសថ

-បានឃើញប្រកាសលេខ០៣៤អបស /មពចុះថ្ងៃទី០៤ខែកក្កដាឆ្នាំ២០១១ស្តីពីការកែសម្រួលបែបបទនិងល័ក្ខខ័ណ្ឌបច្ចេកទេសក្នុងការសុំបើកឬបិទសុំកែទ្រង់ទ្រាយឬប្តូរទីតាំងនៃសេវាវេជ្ជសាស្ត្រអមវេជ្ជសាស្ត្រនិងជំនួយវេជ្ជសាស្ត្រឯកជន

-បានឃើញប្រកាសរួមលេខ ១៤៣២ សហវ.ប្រក ចុះថ្ងៃទី២០ ខែ វិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការកែប្រែកម្រងសេវាសាធារណៈ នៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ៩៩៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ

២០១២ ស្តីពីការផ្តល់សេវាសាធារណៈ របស់ក្រសួងសុខាភិបាល

-បានឃើញប្រកាសរួមលេខ ១៤៣៣ សហវ.ប្រក ចុះថ្ងៃទី២០ ខែ វិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការកែប្រែតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ៩៩៤ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់ រង្វាន់លើកទឹកចិត្តជូនក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញលិខិតលេខ០០៤សជណ/គ.ជ.អ.បចុះថ្ងៃទី២០ខែមករាឆ្នាំ២០១៤របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

-តាមការចាំបាច់របស់ក្រសួងសុខាភិបាល

# សម្រេច

**ប្រការ១.-**

ត្រូវបានកែសម្រួលប្រការ៥ នៃប្រកាស លេខ០៧៧សនប ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៥ ស្តីពីការធ្វើប្រតិភូកម្មមុខងារនៃវិស័យសុខាភិបាល ជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈរបស់ក្រសួងសុខាភិបាល ដូចតទៅ៖

**ប្រការ៥ថ្មី.-**

ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត ត្រូវចាត់មន្ត្រីដែលមានសមត្ថភាពសមស្រប០១ រូប ឲ្យទៅបំពេញការងារជួយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមជំនាញរបស់ខ្លួន ។

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៣.-**

អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការក្រសួងសុខាភិបាល និងប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត មានភារៈអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១៥

ក្រសួងសុខាភិបាល

ម៉ម_ប៊ុនហេង

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-ខុទ្ទកាល័យក្រសួងសុខាភិបាល

-គ្រប់សាលារាជធានី-ខេត្ត

-ដូចប្រការ៥

-ឯកសារ-កាលប្បវត្តិ